# ជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

## អបអរសាទរ ទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤

**យុវជន ខាត់ នរិន្ទ**

*ជាសិស្សថ្នាក់ទី ១០ នៃសាលាចំណេះទូទៅបុរីរិជ្ជា ខេត្តកំពង់ឆ្នាំង*

**ចំណងជើងកំណាព្យ៖ «អំណានលើកកម្ពស់គុណវុឌ្ឍិ និងគុណធម៌»**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- ជីវិតមនុស្សទាំងសកល អំណានបានផ្តល់គ្រឹះមូលដ្ឋាន

២- មួយគឺអប់រំផ្នែកបញ្ញា ពីរសីលធម៌ណាតាមចំណាំ
បីផ្នែកសោភ័ណ បួនពលកម្ម សុខភាពទីប្រាំខ្វះមិនបាន។

៣- ផ្តល់គុណវុឌ្ឍិគឺភាពខ្លាំង គុណធម៌សច្ចំពីអំណាន
អប់រំបណ្តុះគ្រប់មជ្ឈដ្ឋាន ដល់ជនគ្រប់ប្រាណគ្រប់អង្គា។

៤- អំណានបានផ្តល់ចំណេះដឹង ចាត់ចែងថ្លែងថ្លឹងដឹងការងារ
មានជំនាញរឹងគ្រប់វិជ្ជា ព័ត៌មានវិទ្យាជាគំនិត។

៥- អំណានបណ្តុះចំណេះធ្វើ ចេះសព្វសារពើចេះគូរគិត
នវានុវត្តន៍ច្នៃប្រឌិត ដោយពុទ្ធិព្រឹទ្ធពិតប្រាកដ។

៦- អំណានអប់រំសីលសម្បទា មានព្រហ្មវិហារធម៌បួនបទ
ឱ្យចេះរួមរស់ដោយហ្មត់ចត់ ឥរិយាបថត្រូវសម្មាន។

៧- ឥរិយាបថត្រូវទន់ភ្លន់ មានជំនាញទន់ភាពក្លាហាន
ចេះស្នេហាជាតិឱ្យថ្កើងថ្កាន ប្រកាន់ឱ្យបានឧបេក្ខា។

៨- ឥរិយារួមរស់នឹងគ្នា សីលពុទ្ធប្រាំឃ្លាដ៏ថ្លៃថ្លា
មិនប្រមាថគេលួចមុសា សុរាគណ្ហាត្រូវចាកឃ្លាត។

៩- រាប់អានគ្នាដោយភាតរៈ មិននាំហាយនៈកើតវិវាទ
ស្គាល់ព្រំដែនសិទ្ធិមិនបៀនបៀត នាំសង្គមជាតិឱ្យបានថ្កាន។

១០- នាថ្ងៃដប់មួយខែមីនា មាននូវទិវាជាតិអំណាន
បណ្តុះខេមរាឱ្យចំណាន មានគ្រឹះមូលដ្ឋានភាសាខ្មែរ៕

# ជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ

# «ពានរង្វាន់សម្ដេចតេជោ ហ៊ុន សែន»

## អបអរសាទរ ទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤


**យុវតី ឈួ លីយាន**

*ជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យហ៊ុនសែនចំការដូង ខេត្តកែប*


**ចំណងជើងកំណាព្យ៖ «អំណានលើកកម្ពស់គុណវុឌ្ឍិ និងគុណធម៌»**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- អំណានជួយលើកគុណវុឌ្ឍិ វិជ្ជាមោះមុតគ្រប់ភូមិឋាន<br>
អំណានខ្ពង់ខ្ពស់យសថ្កើងថ្កាន អំណានជួយបានគ្រប់វិស័យ។

២- អំណានជួយលើកគុណធម៌ គ្រប់វណ្ណៈពណ៌គុណតម្លៃ<br>
វិស័យអប់រំសមថ្លាថ្លៃ អំណានជួយច្នៃជោគវាសនា។

៣- អំណានជាគ្រឹះនៃជីវិត អំណានថ្កានពិតឫទ្ធិចេស្ដា<br>
អំណានជួយជ្រោងយោងអាត្មា អំណានថ្លៃថ្លាស្គាល់កេរ្តិ៍ឈ្មោះ។

៤- មានសន្តិភាពមានអំណាន ប្រជាសុខសាន្តបានផុតគ្រោះ<br>
ប្រឹងរៀនប្រឹងអានថ្កានសក្តិយស ឧត្តមខ្ពង់ខ្ពស់ឈ្មោះល្បាញល្បី។

៥- ចំណេះចំណានអានចំណាប់ ចំណាំចាំចាប់សព្វសេចក្តី<br>
ទម្លាប់ខ្ជាប់ខ្ជួនក្បួនចាស់ថ្មី ឧស្សាហ៍ឃ្នាតខ្ចីលែលកអាន។

៦- ប្រទេសសម្បូរធនមនុស្ស សេដ្ឋកិច្ចជាតិខ្ពស់រស់ថ្កើងថ្កាន<br>
ដោយសារមានគ្រឹះឫសអំណាន ជួយរុញជួយច្រានបានរឹងមាំ។

៧- អំណានជួយច្រើនមិនស្រយុត ជួយយើងចាកផុតពីភក់ជ្រាំ<br>
កម្ចាត់ភាពខ្លៅឱ្យខ្ទេចខ្ទាំ អំណានជួយនាំនូវរស្មី។

៨- អំណានប្រៀបដូចដួងព្រះចន្ទ ពន្លឺជាក់ស្ប៉ាន់ពេលរាត្រី<br>
ជួយរះបំភ្លឺភពផែនដី ក្មេងចាស់ប្រុសស្រីលែងងងឹត។

៩- ដូចនេះខេមរាទាំងប្រុសស្រី នាំគ្នាឃ្នាតខ្ចីលែលកគិត<br>
ផ្តល់នូវគុណធម៌ជ្រាបជុំជិត ប្រជាមូលមិត្តបានសុខា។

១០- អបអរទិវាជាតិអំណាន អំណរថ្កើងថ្កានបានចែងចារ<br>
ថ្ងៃទីដប់មួយខែមីនា លើកស្ទួយវដ្ដាស្គាល់ជាតិយើង៕

## ជ័យលាភីលេខ៣ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

**អបអរសាទរ ទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤**

**យុវជន បូរិន្ទ ជាដារ៉ាន់**

*ជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យសោមធំ ខេត្តរតនគិរី*

**ចំណងជើងកំណាព្យ៖ «អំណានលើកកម្ពស់គុណវុឌ្ឍិ និងគុណធម៌»**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- អរុណរះណោទ័យវ័យសិក្សា វ័យក្រេបបញ្ញាប្រាជ្ញាចេះ
ព្រះអាទិត្យរះជះចំណេះ បើចង់រៀនចេះគឺត្រូវអាន។

២- អំណានអំណោយស្រស់ត្រកាល វិសេសវិសាលសមុដ្ឋាន
អានច្រើនចេះច្រើនថ្កើងពុំខាន វិសុទ្ធក្សេមក្សាន្តបានសុខផង។

៣- អំណានជួយស្តារអក្ខរខ្មែរ ជួយរក្សាថែមិនឱ្យហ្មង
ទាំងសរសេរអានល្អចម្បង វេយ្យាករណ៍ក្រងតាមតម្រា។

៤- ទិវាខ្ពង់ខ្ពស់រស់អំណាន ជីវិតថ្កើងថ្កានព្រោះប្រាជ្ញា
អំណានប្រសប់កប់ចិន្តា អានច្រើនកាលណាថ្លាគំនិត

៥- ប្រសិនបើអ្នកជាក់រឿងអាន អ្នកប្រាកដបានថ្កានជីវិត
អ្នកដឹងទេថាអស់បណ្ឌិត តែងតែមានមិត្តជាអំណាន។

៦- សាទរអំណានប្រានក្តីខ្ជិល ប្រានសព្វមន្ទិលអស់ពីប្រាណ
ប្រានអស់វិបត្តិខ្វាត់ខ្វាតគ្មានដាន ប្រានល្ងង់សាមាន្យអវិជ្ជា។

៧- សាយណ្តព័ទ្ធមេឃអានឱ្យជាក់ កុំអានឱ្យទាក់ធ្លាក់ពុះពារ
អានបំភ្លឺឋានពសុធា ផ្តោះទៅមាគ៌ាអភិវឌ្ឍន៍។

៨- ត្រូវអានតាមបែបវិទ្យាសាស្ត្រ ឬអក្សរសាស្ត្រឱ្យចាំស្ទាត់
អំណាននាំនវានុវត្តន៍ និងបរិវត្តកម្មសិក្សា។

៩- អំណានថ្កានធម៌គុណវុឌ្ឍិ គុណធម៌មុតដោយហានក្លា
អានលើកកម្ពស់ជាតិសាសនា អានស្នួយប្រាជ្ញាកម្ពុជា។

១០- រាត្រីយើងអានដោយញញឹម អានដោយសង្ឃឹមមិនរួញរា
យើងរីករាយអានទាំងអស់គ្នា មុនចូលនិទ្រាជាសិរី៕